01739868

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

## គម្រោងបញ្ចប់ផែនការ

## កំណែលើកទី ៨

## ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦

**សេចក្តីសង្ខេប**.....2
I. **សេចក្តីផ្តើម**.....3
II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស**.....8
III. **ផែនការបញ្ចប់ការស៊ើបអង្កេត**.....10
IV. **ផែនការបញ្ចប់សវនាការ**.....15
ក. សំណុំរឿង០០២/០២.....16
ខ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុ ក្នុងសំណុំរឿង០០២.....18
គ. សំណុំរឿង០០៣ និង សំណុំរឿង០០៤.....19
V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ**.....19
ក. សំណុំរឿង០០២/០១.....20
ខ. សំណុំរឿង០០២/០២.....23
VI. **សេចក្តីសន្និដ្ឋាន**.....23

ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។

**កំណត់សម្គាល់សម្រាប់អ្នកអាន ៖**

គម្រោងបញ្ចប់ផែនការ អវតក កំពុងតែមានការកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះ រួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿង ដែលនៅសេសសល់ នៃ អ.វ.ត.ក គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្ត នៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការបាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះ ពេលវេលាដែលគ្រោងទុកទាំងឡាយ មិនឆ្លុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗ គ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។

## សេចក្ដីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) ត្រូវបានរៀបចំឡើងជាដំបូងនៅខែ មីនា ឆ្នាំ ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី ៨ នៃ គម្រោងបញ្ចប់ផែនការនេះដែលផុតនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។

សំណុំរឿង ០០២/០១ ព្រឹត្តិការណ៍សំខាន់មួយដែលបានគ្រោងទុក ត្រូវ បានសម្រេច នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបញ្ចប់សវនាការបណ្ដឹងសាទុក្ខចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែ កុម្ភៈ ឆ្នាំ២០១៦។ បច្ចុប្បន្ន អង្គជំនុំជម្រះកំពុងពិភាក្សាសម្រេច និងធញ្ចេញសេចក្ដីព្រាងសាលដីកាបណ្ដឹងសាទុក្ខ។ ដោយ អវត្តមាន ដោយមូលហេតុសុខភាព និង ការចាកចេញនូវទីប្រឹក្សាសំខាន់ម្នាក់ដែលចូលរួមរៀបចំសាលដីកានេះ អង្គជំនុំជម្រះតុលាការកំពូលបានកែសម្រួលពេលវេលាសម្រាប់ការប្រកាសសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ នៅត្រីមាសទី៣ ឆ្នាំ២០១៦។

នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ សវនាការលើភ័ស្តុតាងបានវិវត្តទៅមុខ ដោយបានចាប់ផ្ដើមប្រធានបទទី ៤ ពោលគឺ ស្ដីពីមន្ទីរសន្តិសុខនិងការបោសសំអាតផ្ទៃក្នុង ដែលរួមមាន បទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ពុំមានការប្រែប្រួលដល់គម្រោងពេលវេលាសវនាការដែលបានដឹងមុននោះទេនៅក្នុងបច្ចុប្បន្នភាពនៃគម្រោងបញ្ចប់ផែនការនេះ។

ទន្ទឹមនឹងនេះក៏មានការរីកចម្រើនច្រើនក្នុងរយៈពេលត្រីមាសចុងក្រោយនេះ ក្នុងផ្នែកស៊ើបសួរក្នុងសំណុំរឿង ០០៣ និង សំណុំរឿង០០៤។ អោ អាន ត្រូវបានចោទប្រកាន់មួយផ្នែក នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។ នៅពេលបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ អោ អាន ត្រូវសហចៅក្រមស៊ើបអង្កេតអន្តរជាតិចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបន្ថែមទៀត។ សំណើសុំមោឃភាពដែលបានដាក់ពេលថ្មីៗនេះក្នុងករណីប្រឆាំងនឹង អ៊ឹម ចែម អាចនឹង ពន្យារពេលដល់ការចេញដីកាដំណោះស្រាយ រហូតដល់៣ខែ ក្នុងសំណុំរឿងរបស់គាត់។

01739870

លំហូរនៃគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦។

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩”[1]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[2]។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញគិតទុកជាមុនថានៅពេលខាងមុខខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៨ ប្រចាំត្រីមាសនៃគម្រោង

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] នៅក្នុងសេចក្តីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្តីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៤។ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្តង ២០១៤-២០១៥” B, I, កថាខណ្ឌទី៨។

បញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦។

៣ ឯកសារនេះផ្ដោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្ដល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្ដី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេបន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[3]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក ត្រូវចាត់ការតាមនីតិវិធី។

៤ មកដល់ពេលនេះអង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះ សំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្ដី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបាន

[3] សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្ដីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្ដីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

ផ្តន្ទាទោសម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំ សេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

៥ ដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ កំពុងតែអនុវត្ត។ អង្គជំនុំជម្រះតុលាការកំពូលបានដំណើរការសវនាការលើបណ្តឹងសាទុក្ខលើកដំបូងរបស់ខ្លួននៅថ្ងៃទី ២ ទី ៣ និង ទី ៦ ខែកក្កដា ឆ្នាំ ២០១៥ ហើយសវនាការលើបណ្តឹងសាទុក្ខបន្ថែមទៀត ដំណើរការ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥និងសវនាការបណ្តឹងសាទុក្ខចុងក្រោយនៅចន្លោះថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថាសំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម លើប្រធានបទ ការប្រព្រឹត្តិលើ ចាម វៀតណាម និងពុទ្ធសាសនិក អាពាហ៍ពិពាហ៍ដោយបង្ខំ រំលោភសេពសន្ថវៈ មន្ទីរសន្តិសុខនិង សហករណ៍ ។ សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ នៅត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួន ៧៦ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៣៨ នាក់ និងអ្នកជំនាញ៣នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានស្តាប់សក្ខីកម្មក្នុងអំឡុងពេលពេលសវនាការដែលរៀបចំជាក់លាក់សម្រាប់ការស្តាប់សក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេ ណីនៅតាមសហករណ៍ និងការដ្ឋាន ព្រមទាំងពាក់ព័ន្ធនឹងការប្រព្រឹត្តិលើចាម និង វៀតណាម។

៧ បច្ចុប្បន្ន សំណុំរឿង០០៣ និង ០០៤ កំពុងតែស្ថិតក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មទៅលើសំណុំរឿងទាំងនេះ ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ជនត្រូវចោទ៤នាក់។ មានការបន្តរីកចម្រើនជាច្រើន ទៅលើសំណុំរឿងទាំងពីរនេះនៅក្នុងអំឡុងត្រីមាសទី ១ ឆ្នាំ២០១៦។ អោ អាន ត្រូវបានចោទដោយផ្នែក នៅថ្ងៃទី២៧ ខែមីនា

ឆ្នាំ២០១៥ ហើយត្រូវបានចោទបន្ថែមទៀតនៅពេលចូលមកបង្ហាញខ្លួនលើកដំបូងម្តងទៀតនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពីបទល្មើសសំខាន់ៗដែលនៅសល់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា មានភស្តុតាងច្បាស់លាស់និងស៊ីសង្វាក់។ រឿងក្តីប្រឆាំងនឹង អ៊ឹម ចែម ត្រូវបានបំបែកជាសំណុំរឿង០០៤/០១ នៅថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០១៦។

៨ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ មានព្រឹត្តិការណ៍សំខាន់ចំនួន១២សម្រាប់សំណុំរឿងចំនួន៣ដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[4] និង ការព្យាករណ៍ដែលបន្តពាក់ព័ន្ធគឺ៖

(i) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (ត្រឹមត្រីមាសទី៣ ឆ្នាំ ២០១៦)

(ii) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រឹមត្រីមាសទី៤ ឆ្នាំ២០១៦)

(iii) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៧)

(iv) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៤ ឆ្នាំ២០១៧)

(v) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី១ ឆ្នាំ២០១៨) និង

(vi) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទី៣ ឆ្នាំ២០១៩)

៩ នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤ និង សំណុំរឿង០០៤/០១ ព្រឹត្តិការណ៍ដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរ ដែលនៅសេសសល់ ហើយក្នុងករណីមានការចោទ

---

[4] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃសំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែ មេសា ឆ្នាំ ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

01739874

ប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះនិងបណ្តឹងសាទុក្ខ[5]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺ៖

(vii) សេចក្តីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទី៣ ឆ្នាំ២០១៦)

(viii) សេចក្តីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរដែលនៅសេសសល់ក្នុងសំណុំរឿង០០៤ (ត្រីមាសទី២ និង/ឬត្រីមាសទី៤ ឆ្នាំ២០១៦ អាស្រ័យទៅលើការបំបែកកិច្ចនីតិវិធីណាមួយ) ។

(ix) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេច ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៦)។

(x) ការចេញដីកាដំណោះស្រាយ(១ឬច្រើន) ក្នុងសំណុំរឿង០០៤ និង០០៤/០១ ជាមួយនឹងសេចក្តីសម្រេចថាតើ ត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី(នៅត្រីមាស៣ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៤/០១ និង ត្រីមាសទិ៤ ឆ្នាំ២០១៦ និង/ឬ ត្រីមាសទី២ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៤ អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់)។

(xi) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុង សំណុំរឿងនោះ (ត្រីមាសទី២ ឆ្នាំ២០១៧ ។

(xii) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយមួយ(ឬច្រើន)ក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ(ត្រីមាសទី៤ ឆ្នាំ២០១៧)

---

[5] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៣៨ ខាងក្រោម ដោយសាស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១០ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-១០១៥សម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកា និងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ប៉ុន្តែ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់ប្រាក់ បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិក ជាតិនៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្តោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១១ ក្រោយពីមានការសម្រេចផ្តល់ការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិ (សេចក្តីសម្រេចលេខ ៧០/២៤៨) ជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេចកំណត់ទឹកប្រាក់ចំនួនមិនលើសពី ១២,១ លានដុល្លារដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិ នៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី ១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។ សកម្មភាពទាន់ពេលវេលានេះនឹងជួយសម្រួលយ៉ាងសំខាន់ដល់ប្រតិបត្តិការកុំឲ្យរអាក់រអួលនៅត្រីមាសទី១ ឆ្នាំ២០១៦ ដោយបើកឱកាសឲ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់វិភាគទានដោយផ្ទាល់ម្តងទៀតគិតត្រឹមឆ្នាំ២០១៥ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ៦ខែដំបូង ក៏ដូចជា ចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៦ គឺជាវិធានការបង្គ្រប់ដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្ន របស់ភាគីជាតិនៃអ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថាដំណាក់កាលដែលមានទំហំការងារច្រើនបំផុតបច្ចុប្បន្ននៅក្នុងកិច្ចការរបស់អ.វ.ត.ក គឺបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ចឆ្ពោះទៅឆ្នាំ២០១៦។ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះនិងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និង ថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ នឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែក

ហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើង យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១២ ការប៉ាន់ស្មាននានាលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និង ការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ សន្មត់ថាសកម្មភាពទាំងអស់ នឹងបន្តអនុវត្តដំណាល១គ្នា។ សហព្រះរាជអាជ្ញា ក៏នឹងចូលរួមក្នុងពេលជាមួយគ្នាដែរនៅក្នុងការជំនុំជម្រះក្តី និង នីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ ព្រមទាំងការស៊ើបអង្កេត និង ការរៀបចំ សារណាបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០៣ និង ០០៤។

១៣ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធាន ផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរឬក៏ណាវិសាលភាពស៊ើបអង្កេតដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ តាមការចោទប្រកាន់។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងអាចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះក្តីដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិសោធនកម្មទាំងនេះ ប្រសិនបើ អនុវត្តបាន គឺអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តវាយតម្លៃទៅលើថាតើវិធានថ្មីទាំងនេះអាចយកមកអនុវត្តដើម្បីពង្រួញវិសាលភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ដែរឬយ៉ាងណា។

១៤ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញឲ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មវិធីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀតដើម្បីបង្កើនផលិតផលនៃកិច្ចស៊ើបសួរ។ សមត្ថភាពបំពេញកិច្ចស៊ើបសួរត្រូវបានបង្កើន ថែមទៀត នៅពេលដែលអ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបានចូលបម្រើការងារនៅក្នុងការិយាល័យ សហចៅក្រមស៊ើបអង្កេតក្នុងត្រីមាសទី១ ឆ្នាំ២០១៥។ អ្នកស៊ើបអង្កេតអន្តរជាតិថ្មីបីរូបបំពេញកិច្ចការនេះក្នុង

រយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជា សមាជិក និង អង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសអ្នកស៊ើបអង្កេតបន្ថែមមកបំពេញការងារជាបុគ្គលិកមិនយកប្រាក់កម្រៃ។

១៥ ការិយាល័យរដ្ឋបាលបានរក្សាទុកសេវាបកប្រែភាសាក្រៅក្របខ័ណ្ឌមួយចំនួន ដើម្បីជួយការងារការិយាល័យ និងអង្គជំនុំជម្រះ ដើម្បីធានាឲ្យមានសេវាបកប្រែភាសាបានទាន់ពេលវេលា។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៦ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើងក្រោយពីមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៩។ ចាប់តាំងពីពេលនោះមក សហព្រះរាជអាជ្ញាអន្តរជាតិក៏បានដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយចំនួនទៀត។ សហចៅក្រមស៊ើបអង្កេតជាតិនិងអន្តរជាតិបានធ្វើកំណត់ហេតុខ្វែងយោបល់គ្នាទាក់ទិននឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ ហើយកំពុងតែប្រកាន់យកវិធីសាស្ត្ររៀងៗខ្លួន។ ទោះជាមានទស្សនៈខុសគ្នាទៅលើបញ្ហាច្បាប់ និងបញ្ហាអង្គហេតុជាក់លាក់មួយចំនួនក៏ដោយ ក៏កិច្ចសហការវិជ្ជាជីវៈរវាងចៅក្រមទាំងពីររូបនៅតែបន្តមានលក្ខណៈប្រសើរដដែល។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងតែបំពេញកិច្ចស៊ើបសួរយ៉ាងសកម្មទៅលើការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ នៅក្នុងសំណុំរឿង ០០៣ និង ០០៤។

១៧ តារាងកំណត់ពេលវេលានៃការស៊ើបអង្កេតដែលកំពុងតែបន្ត ស្ថិតក្រោយឥទ្ធិពលនៃកត្តានានាដូចជាៈ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវផ្តល់សក្ខីកម្ម ចំនួនបេសកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមានបុគ្គលិកមានគុណវុឌ្ឍិ និងសមត្ថភាពក្នុងការរក្សាទុកបុគ្គលិកដែលមានបទពិសោធន៍ និងការបង្អាក់ជាក់ស្តែងនិងធនធានសម្ភារៈដែលអាចប៉ះពាល់ដល់ការបំពេញកិច្ចស៊ើបសួរ។ នៅក្នុងបរិបទនេះ ជាការសំខាន់ណាស់ក្នុងការបញ្ជាក់ថា ការស៊ើបអង្កេតនានាមិនអាចអនុវត្តបាន ដូចៗគ្នានិងជាទៀងទាត់ទេនៅគ្រប់ពេលទាំងអស់ពេញមួយឆ្នាំតែម្តងដូចជានៅក្នុងបរិយាកាសដទៃទៀតដែរ។ ថ្ងៃឈប់សម្រាកបុណ្យជាតិមានចំនួនច្រើនហើយនៅអំឡុងពេលនោះបុគ្គលិកជំនួយការមិនមានពេលជួយស្តាប់ចម្លើយឡើយ។ ជាងនេះទៀតនៅអំឡុងពេលរដូវវស្សានិងច្រូតកាត់ សាក្សីសក្តានុពលកម្រ

នឹងផ្តល់ចម្លើយណាស់ ។ មិនតែប៉ុណ្ណោះ ទីតាំងដាច់ស្រយាលជាក់ស្តែងយើង មិនអាចទៅបំពេញបេសសកម្មក្នុងអំឡុងពេលមួយចំនួនក្នុងរដូវវស្សា។

១៨ ចំនួនញត្តិដែលដាក់ដោយភាគី និងពេលវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំក៏ប៉ះពាល់ទៅលើក្របខ័ណ្ឌពេលវេលាដែរ។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តអាចផ្អែកលើបទពិសោធន៍កន្លងទៅ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនអាចចាត់ទុកឲ្យលើសពីការប្រមាណទុកមួយនោះឡើយ។ ជាការសំខាន់ផងដែរគឺត្រូវយល់ ថាកត្តាមួយចំនួនដូចរៀបរាប់ខាងលើពិតជាមិនអាចគ្រប់គ្រងបាន ហើយការធ្វើផែនការពេលវេលារបស់សហចៅក្រមស៊ើបអង្កេតក៏មានលក្ខណៈដូចគ្នាទៅតាមកាលៈទេសៈនោះដែរ។

១៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបានអ្នកធ្វើការបន្ថែមពីសំណាក់រដ្ឋជាសមាជិក អ្នកហាត់ការ និង បុគ្គលដែលមានគុណវុឌ្ឍិខ្ពស់ ដែលធ្វើការដោយមិនយកកម្រៃ។ ប្រការនេះធ្វើឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតងាយរងផលប៉ះពាល់នៅក្នុងករណីដែលបុគ្គលិកទាំងនោះត្រឡប់ទៅវិញ ហើយវាក៏ប៉ះពាល់ដល់លទ្ធភាពក្នុងការស្រូបយកបន្ទុកកិច្ចការបន្ថែមទៀតផងដែរ ដែលបន្ទុកកិច្ចការនេះកើតចេញពីការដាក់ឯកសារតុលាការរបស់ភាគី និង/ឬ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ។ បុគ្គលិកមានបទពិសោធន៍មួយចំនួនបានលាលែងពីការងារនៅអំឡុងត្រីមាសទី១ ឆ្នាំ២០១៦ ហើយការជ្រើសរើសនិងបណ្តុះបណ្តាលបុគ្គលិកថ្មីគឺត្រូវការពេលវេលា។

២០ វិធានផ្ទៃក្នុងបញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវតែស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅ ក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឲ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ។ ភាគីនានាអាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួនហើយការណ៍នេះអាចតម្រូវឲ្យមានការកិច្ចការស៊ើបអង្កេតយ៉ាងច្រើនអាស្រ័យទៅលើករណីនោះ។ ការបដិសេធមិនពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរ អាចនឹង

ត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ហើយផ្អែកលើ ពិសោធន៍កន្លងមកគឺថា អង្គជំនុំជម្រះអាចតម្រូវរហូតដល់៦ ខែ ដើម្បីសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍បែបនេះ។ វាអាស្រ័យទៅលើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ និងលទ្ធផល ដែលសេចក្ដីសម្រេចនានាអាចមានផលប៉ះពាល់យ៉ាងច្រើនទៅលើការស៊ើបអង្កេតដែលកំពុងតែដំណើរការហើយវាបន្ថែមយ៉ាងច្រើនទៅលើពេលវេលាដែលចាំបាច់ដើម្បីបញ្ចប់កិច្ចការនេះ។ ករណីនេះ ដូចគ្នាទៅនឹងសំណើសុំមោឃភាព នៅអង្គបុរេជំនុំជម្រះ ទាក់ទិននឹងកិច្ចស៊ើបសួរ ដែលមិនរងការចោទប្រកាន់ថាមិនស្របច្បាប់ ពីព្រោះថា សហចៅក្រមស៊ើបអង្កេតមិនមានអំណាចធ្វើមោឃភាពទៅលើកិច្ចស៊ើបសួររបស់ខ្លួនឯងបានឡើយ។

២១ នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេត ជូនដំណឹងដល់ភាគីទាំងអស់ដែលរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមលើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើដែលបានដាក់ជូន សហចៅក្រមស៊ើបអង្កេតត្រូវតែចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ដូច្នេះ អាចមានការពន្យារពេលដែលមិនអាចស្មានបាន។ នៅពេលដែលរយៈពេលនេះបានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឱ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និងបង្វិលសំណុំរឿងឱ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទ ត្រូវបានឃុំខ្លួន និងរយៈពេល៣ខែនៅក្នុងរឿងក្ដីផ្សេងទៀត។ បច្ចុប្បន្ននេះពុំទាន់មានជនត្រូវចោទណាម្នាក់ត្រូវបានឃុំខ្លួននៅឡើយទេ។ ទាល់តែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ ទើបសហចៅក្រមស៊ើបអង្កេតអាចនឹងចេញដីកាដំណោះស្រាយ ថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនជនត្រូវ ចោទទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។

២២ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់បណ្ដឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធ

ចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះដែរ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្ដល់នូវសិទ្ធិឱ្យជនត្រូវចោទ ជំទាស់ នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្ដឹងឧទ្ធរណ៍។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២៣ ក្រោយពីមានការចោទប្រកាន់បន្ថែមនៅខែធ្នូ ឆ្នាំ២០១៥ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ប្រឆាំងនឹង មាស មុត ចេះតែបន្តទៅមុខ។ ក្នុងសំណុំរឿង០០៤ យឹម ទិត្យ បច្ចុប្បន្ន កំពុងតែចូលរួមយ៉ាងពេញលេញក្នុងដំណើរការនីតិវិធីក្រោយពេលដែលមេធាវីការពារក្ដីរបស់គាត់ត្រូវបានផ្ដល់សិទ្ធិចូលពិនិត្យសំណុំរឿង នៅខែធ្នូ ឆ្នាំ២០១៥។

២៤ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបង្គាប់ឲ្យបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង០០៤។ សំណុំរឿងថ្មីមួយលេខ ០០៤/០១ ត្រូវបានបង្កើត ហើយបច្ចុប្បន្ន សំណុំរឿងនេះកំពុងតែដំណើរការដាច់ដោយឡែកពីសំណុំរឿង០០៤។ ដំណាក់កាលនីតិវិធីបន្ទាប់ឆ្ពោះទៅចេញដីកាដំណោះស្រាយ គឺការបញ្ជូនសំណុំរឿង០០៤/០១ ទៅការិយាល័យសហព្រះរាជអាជ្ញាដើម្បីពិនិត្យ និងចេញសេចក្ដីសន្និដ្ឋានស្ថាពរ រួចហើយជូនមេធាវីការពារក្ដីសម្រាប់ការឆ្លើយតប។ ប៉ុន្តែ សំណើសុំមោឃភាពកិច្ចស៊ើបសួរត្រូវបានដាក់ក្នុងរឿងក្ដីនេះ ហើយគេរំពឹងថាប្រការនេះនឹងធ្វើឲ្យមានការពន្យារពេលដល់ទៅ៣ខែ។

២៥ វិធីមួយដែលសហចៅក្រមស៊ើបអង្កេតនៅតែពេញចិត្តបន្តអនុវត្តនៅក្នុងសំណុំរឿង០០៤ នោះ គឺការបំបែកសំណុំរឿង ចំពោះនីតិវិធីប្រឆាំងនឹង អោ អាន ខណៈពេលដែល ការស៊ើបអង្កេតជិតដល់ទីបញ្ចប់។

២៦ ចាប់តាំងពីដំណាក់កាលដំបូងនៃការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង សំណុំរឿង០០៤មក មានការចុះទៅបំពេញបេសកកម្មចំនួន២២១លើក និងស្ដាប់ចម្លើយសាក្សីចំនួន១២១១លើក។ នៅក្នុងអំឡុងពេលត្រីមាសទី១ ឆ្នាំ២០១៦ បានបំពេញបេសកកម្មចំនួន២០លើក ហើយស្ដាប់ចម្លើយសាក្សីបាន១០២លើក ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចុះអនុស្សរណៈនៃការយោគយល់គ្នា មួយមជ្ឈ

មណ្ឌលឯកសារកម្ពុជាបានដែលអនុញ្ញាតឲ្យមានការបំប្លែងឯកសារសោតទស្សន៍ទាំងអស់ដែលមាន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទៅជាឯកសារឌីជីថល ក្នុងគោលបំណងដាក់ក្នុងសំណុំរឿង។

២៧ ការប៉ាន់ស្មានដ៏ល្អបំផុតដែល អាចផ្តល់ជូនបាននៅពេលនេះគឺ៖

- កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ទាក់ទិននឹង មាស មុត នឹងត្រូវបញ្ចប់ ត្រឹមពាក់កណ្តាល ត្រីមាសទី៣ ឆ្នាំ ២០១៦។
- កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ នឹងបញ្ចប់នៅចុងត្រីមាសទី២ ឆ្នាំ២០១៦ សម្រាប់ ជនត្រូវចោទ អោ អាន រួចហើយនឹងមានដីកាបំបែកសំណុំរឿង។ កិច្ចស៊ើបសួរលើករណី យឹម ទិត្យ នឹងបញ្ចប់ នៅចុងត្រីមាសទី៤ ឆ្នាំ២០១៦។
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ នឹងត្រូវចេញនៅត្រីចុងមាសទី៤ ឆ្នាំ ២០១៦
- ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម នឹងត្រូវចេញនៅចុង ត្រីមាសទី៣ ឆ្នាំ២០១៦ ។
- ដីកាដំណោះស្រាយទាក់ទិននឹងបទចោទប្រឆាំងនឹង អោ អាន នឹងចេញនៅត្រីមាសទី៤ ឆ្នាំ ២០១៦។ ដីកាដំណោះស្រាយទាក់ទិននឹងបទចោទប្រឆាំងនឹង យឹម ទិត្យ នឹងចេញនៅ ត្រីមាសទី២ ឆ្នាំ២០១៧។
- រាល់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយនឹងត្រូវសម្រេចសេចក្តីដោយអង្គបុរេជំនុំជម្រះនៅត្រីមាសទី២ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៣ និងត្រីមាសទី៤ ឆ្នាំ២០១៧ សម្រាប់សំណុំរឿង០០៥។

២៨ ការប៉ាន់ប្រមាណពេលវេលាទាំងនេះនៅតែអាស្រ័យទៅលើកត្តាជាច្រើន ក្នុងនោះមានដូចដែលបាន កំណត់កាលពីមុន ដូចជា៖ ពុំមានការចាកចេញ របស់បុគ្គលិកសំខាន់ៗ ថវិកាគ្រប់គ្រាន់សម្រាប់ ជ្រើសរើសបុគ្គលិកថ្មីនិងមានគុណវុឌ្ឍិ ទៅតាមតំណែងដែលនៅទំនេរ ការបកប្រែឯកសារ ទាន់ពេល វេលាសមត្ថភាពបកប្រែផ្ទាល់មាត់និងការធ្វើប្រតិចារឹក គ្រប់គ្រាន់សម្រាប់បេសកកម្មនៅនៅតាម

មូលដ្ឋាន និង ការស្តាប់ចម្លើយសាក្សី ដំណោះស្រាយទាន់ពេល វេលាទៅលើបណ្តឹងឧទ្ធរណ៍នៅអង្គបុរេជំនុំជម្រះ និង ការគាំទ្រពេញលេញពីសំណាក់នគរបាលយុត្តិធម៌ ។

## IV. ផែនការបញ្ចប់សវនាការ

២៩ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និងការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

៣០ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្តានុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគីព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភ័ស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្តុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្តី។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើ

ទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

ក. <u>សំណុំរឿង០០២/០២</u>

៣១ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្តាហ៍។លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះបានស្តាប់ សក្ខីកម្មសាក្សីសរុបចំនួន៧៦ ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន៣៨ និង អ្នកជំនាញចំនួន៣នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើជនជាតិចាម) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង និងភ្នំក្រោល។ អង្គជំនុំជម្រះរំពឹងថានឹងចាប់ផ្តើមសវនាការលើភស្តុតាងទាក់ទិននឹងស២១ ដែលជាមន្ទីរសន្តិសុខចុង ក្រោយគេបង្អស់ ដែលមាននៅក្នុងសំណុំរឿង០០២/០២ នៅអំឡុងត្រីមាសទី២ ឆ្នាំ២០១៦។ បន្ទាប់មកនឹងមានសវនាការទាក់ទិននឹងប្រធានបទសវនាការដែលនៅសេសសល់ មានជាអាទិ៍៖ ការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ។

៣២ ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ គឺអាចស្មានទុកបានក្នុងសំណុំរឿង ០០២/០២ តែនៅពេល ចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៦៥ ត្រូវបានស្នើឡើងដំបូងដោយភាគី។ សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីថ្មីបន្ថែមចំនួន ៤៥ នាក់ទៀត ព្រមទាំងអ្នកជំនាញ១នាក់ ត្រូវបានស្នើឡើងចាប់តាំងពីការចាប់ផ្តើមការជំនុំជម្រះមកម្ល៉េះ។ ការស្មានទុកពេលទាក់ទិននឹងសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថា សវនាការទីពីរនឹងមានលក្ខណៈ

ស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការ០០២/០១ ដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវបានកំណត់ពេញលេញ។

៣៣ នៅក្នុងផែនការបញ្ចប់គម្រោងដែលធ្វើបច្ចុប្បន្នភាពលើកមុន អង្គជំនុំជម្រះបានវាយតម្លៃនូវផលប៉ះពាល់រួមកើតចេញពីពិហិការរបស់មេធាវីការពារក្តី នៅក្នុងត្រីមាសចុងក្រោយឆ្នាំ២០១៤ ការផ្អាកកិច្ចនីតិវិធីតុលាការសម្រាប់ពិនិត្យមើលការដាក់ បង្ហាញ ឯកសារពីសំណុំរឿង០០៣ និង សំណុំរឿង ០០៤និងពេលវេលាដែលផ្តល់ជូនភាគីក្នុងការរៀបចំចូល រួមក្នុងសវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ ទោះបីជាកត្តាទាំងនេះជារួមបណ្តាលឲ្យ មានការបាត់បង់ពេលវេលាសវនាការចំនួនជាង ៤ខែក៏ដោយ ប៉ុន្តែ ការរីកចម្រើនដែលអង្គជំនុំសម្រេច បាននៅក្នុងការការជំនុំជម្រះក្តីសំណុំរឿង ០០២/០២ ជាពិសេស រយៈពេល៦ខែដំបូងឆ្នាំ២០១៥ នោះ បានបង្កើតភាពចាំបាច់ក្នុងការរំកិលគ្រោងការដែលរំពឹងទុកសម្រាប់បិទបញ្ចប់កិច្ចនីតិវិធី សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និង ការចេញសាលក្រមក្នុងរយៈពេលកំណត់តែ៣ខែ ប៉ុណ្ណោះ ក្នុងកិច្ចនីមួយៗ។ ចាប់តាំងពីការចាប់ផ្តើមសវនាការលើភស្តុតាង នៅខែមករា ឆ្នាំ២០១៥មក ពុំឃើញមានសញ្ញាណនៃការធ្វើពហិការពីសំណាក់មេធាវីការពារក្តីក្នុងសវនាការសំណុំរឿង០០២/០២ឡើយ។

៣៤ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ចាំបាច់ត្រូវតែពិនិត្យមើលឡើងវិញនូវស្ថានការណ៍សាជាថ្មី នៅពាក់កណ្តាលឆ្នាំ២០១៦ ដើម្បីសម្រេចថាតើការព្យាករណ៍ទុកទាំងនេះនៅតែមានភាពសុក្រឹតដោយឈរលើមូលដ្ឋាននៃស្ថានភាពជំនុំជម្រះក្តីនៅពេលនោះដែរឬយ៉ាងណា។ ជាការច្បាស់ណាស់ថាមុនពេលនោះ មានកត្តាមួយចំនួនដែលទំនងជាផ្តល់ផលប៉ះពាល់បន្ថែមទៀតដល់កាលវិភាគ។ ឧទាហរណ៍ ការដាក់បង្ហាញឯកសារ បន្ថែមទៀតពីសំណុំរឿង០០៣ និង សំណុំរឿង០០៤ ក៏គេប្រមើលឃើញផងដែរ ហើយអាចផ្អាកដំណើរការនីតិវិធីជាមិនខាន។ ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាបានបង្ហាញថា ចម្លើយពាក់ព័ន្ធ ភាគច្រើន ពីសំណុំរឿង០០៣ និង ០០៤ ដែលខ្លួនមានបច្ចុប្បន្ន ត្រូវបានដាក់បង្ហាញរួចហើយនៅក្នុង សំណុំរឿង០០២/០២ ដូច្នេះ ការណ៍ការពន្យារពេលនៅថ្ងៃអនាគតដែលបណ្តាលមកពីការដាក់បង្ហាញ ឯកសារបន្ថែម ទំនងជាមិនយូរដូចកាលពីឆ្នាំ២០១៥នោះទេ។

៣៥ អង្គជំនុំជម្រះសាលាដំបូងក៏បានចាត់វិធានការដើម្បីកម្រិតបន្ថែមលើដំណើរការដាក់បង្ហាញឯកសារ ដោយប្រកាសថា សហព្រះរាជអាជ្ញាមានកាតព្វកិច្ចបន្តក្នុងការដាក់បង្ហាញចំពោះមេធាវីការពារក្តីនូវ

ភស្តុតាងដោះបន្ទុក ដែលមានសម្ភារៈឯកសារដែលសហព្រះរាជអាជ្ញាបានដឹង ដែលអាចបញ្ជាក់អំពីភាពគ្មានពិរុទ្ធភាព ឬសម្រាលដល់ពិរុទ្ធភាពរបស់ជនជាប់ចោទ ឬដែលអាចប៉ះពាល់ដល់ភាពអាចជឿបាននៃភស្តុតាងដាក់បន្ទុក ហើយដោយក្នុងនោះ បង្គាប់ឲ្យសហព្រះរាជអាជ្ញាស្នើសុំការទទួលយកយ៉ាងយូរបំផុតនៅត្រឹមខែមករា ឆ្នាំ២០១៦ នូវសម្ភារៈឯកសារសំណុំរឿង០០៣ណិង០០៤ ដែលបានដាក់បង្ហាញមកទល់នឹងពេលនេះ ក្នុងសំណុំរឿង០០២/០២ ហើយដែលពួកគេមានបំណងយកជាមូលដ្ឋានសំអាង។

៣៦ កក្តាដទៃៗទៀត ដែលអាចពាក់ព័ន្ធនឹងរយៈពេលជំនុំជម្រះក្តីដែលស្មានទុកដែលអាចកើត ឡើងនៅពេលអនាគត រួមមានការប្រែប្រួលសុខភាពរបស់ជនជាប់ចោទ ដែលតម្រូវឲ្យមាន ការកាត់បន្ថយចំនួនថ្ងៃសនាការក្នុង១សប្តាហ៍និង/ឬរយៈពេលនៃថ្ងៃសវនាការនីមួយ ក៏ដូចជាភាពទំនេរ របស់សាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងកំពុងតែតាមដានស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។ ថ្មីៗនេះ អង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញវេជ្ជសាស្រ្តធ្វើការវាយតម្លៃផ្នែក រាងកាយ និងចិត្តសាស្រ្ត ទៅលើជនជាប់ចោទ និង វាយតម្លៃសម្បទារបស់ពួកគាត់ក្នុងការបន្តចូលរួមក្នុងនីតិវិធីសវនាការ។ បច្ចុប្បន្នកំពុងតែរៀបចំកាលវិភាគចំពោះការពិនិត្យលើសម្បទាដែលនឹងធ្វើឡើងនៅចុងខែកក្កដា ឆ្នាំ២០១៦។

៣៧ អង្គជំនុំជម្រះក៏បានសម្តែងការព្រួយបារម្ភបន្ថែមជូនចំពោះ ការិយាល័យ រដ្ឋបាលអំពីការបកប្រែ និងភាពទំនងជាអាចមានការពន្យារពេលប្រសិនបើការព្រួយ បារម្ភទាំងនេះមិន ត្រូវបានដោះស្រាយ។ ការិយាល័យរដ្ឋបាលបានចាត់វិធានការនានាដើម្បីដោះស្រាយ បញ្ហានេះ និងបន្តពិនិត្យមើលបញ្ហានោះទៅតាមការវិវត្តជាក់ស្តែង។

## ខ. <u>បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុ ក្នុងសំណុំរឿង០០២</u>

៣៨ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្រប របស់អង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថាអង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ច

01739886

កាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាមក្រមខ័ណ្ឌគតិយុត្តិ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។ មកដល់ពេលនេះ អង្គជំនុំជម្រះពុំទាន់បានទទួលសំណើណាមួយទាក់ទិននឹងបញ្ហានេះទេ។ បញ្ហានេះនៅតែស្ថិតក្នុងការពិចារណាដដែល។

គ. <u>សំណុំរឿង០០៣ និង សំណុំរឿង០០៤</u>

៣៩ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាចធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

៤០ ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដំណាក់កាលនៃបណ្តឹងសាទុក្ខធំៗចំនួនបីត្រូវតែញែកដូចតទៅ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខក្នុងរយៈពេល៣០ ថ្ងៃក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណីដែលមានបណ្តឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ ថ្ងៃទៀត ដើម្បីដាក់សេចក្តីសុំប្តឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ភាគីនឹងមានរយៈពេល១០ថ្ងៃក្នុង ការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែកាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្តល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែលពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ ដោយត្រូវគោរពតាមលក្ខខណ្ឌមួយចំនួន ភាគីក៏មានសិទ្ធិស្នើសុំស្តាប់ភស្តុតាងបន្ថែមនៅក្នុងបណ្តឹង

សាទុក្ខ ដែលអាចតម្រូវឲ្យអង្គជំនុំជម្រះតុលាការកំពូលរៀបចំសវនាការពិនិត្យភ័ស្តុតាង។ បណ្តឹងសាទុក្ខ ដែលភាគីធ្វើសារណាលើអង្គហេតុដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ អាចត្រូវបានបង្គាប់ឲ្យធ្វើ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូល និងនៅពេលមានការសម្រេចលើសំណើសុំភ័ស្តុតាងបន្ថែមរួចហើយនោះ។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

ក. <u>សំណុំរឿង០០២/០១</u>

៤១ ក្រុមមេធាវី នួន ជា និង ខៀវ សំផន បានជូនដំណឹងអំពីបណ្តឹងសាទុក្ខនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ និង សារណាលើបណ្តឹងសាទុក្ខនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ដោយបាន ពង្រឹងមូលដ្ឋានបណ្តឹងសាទុក្ខចំនួន២២៣ (មេធាវីការពារក្តី នួន ជា) និង ១៤៨(មេធាវីការពារក្តី ខៀវ សំផន) ដែលក្តោបស្ទើរតែទាំងអស់ទៅ លើសំអាងហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំ រឿង ០០២/០១ ព្រមទាំង សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនត្រូវអនុញ្ញាតឲ្យប្តឹងសាទុក្ខភ្លាមៗ រហូតដល់ចេញសាលក្រមលើអង្គសេចក្តី។ មិនតែប៉ុណ្ណោះ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាក៏ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលស្នើសុំត្រឹមតែការបំភ្លឺបញ្ជាក់ពីអង្គជំនុំជម្រះតុលាការ កំពូលទាក់ទិននឹងការអនុវត្តទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ដែលគេហៅថា "សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣"។ សារណាបណ្តឹងសាទុក្ខនោះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ០១៤។

៤២ សំណៅបកប្រែជាភាសាខ្មែរ នៃសារណារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីត្រូវបានបញ្ចប់នៅក្នុងខែសីហា និងខែកក្កដា ឆ្នាំ២០១៥។ សវនាការលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខមិនអាចកំណត់ពេលវេលាបានទេ រហូតទាល់តែសារណា និងសារណាតបមានជាភាសាខ្មែរ និងអង់គ្លេសឬបារាំង។ ហេតុដូច្នេះកត្តាមួយទៀតដែលប៉ះពាល់យ៉ាង ខ្លាំងដល់ដំណើរការនីតិវិធីបណ្តឹង សាទុក្ខបានបង្ហាញឲ្យឃើញថាវា អាស្រ័យទៅលើការបកប្រែសារណាបណ្តឹងសាទុក្ខ ជាពិសេសការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរ។

៤៣ បន្ថែមលើការដាក់សារណាលើអង្គសេចក្តីនៅក្នុងបណ្តឹងសាទុក្ខ ការណ៍ដែលថា មេធាវីការពារក្តី នួន ជា បានអនុវត្តសិទ្ធិផ្នែកនីតិវិធីយ៉ាងច្រើនរបស់គាត់ ហើយបានដាក់ញត្តិចំនួន ៦ ដាច់ដោយឡែកពីគ្នា សម្រាប់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខចាប់តាំងពីការចេញសាល ក្រមក្នុងសំណុំរឿង០០២/០១ នោះគឺក៏បានប៉ះពាល់ដល់គម្រោងពេលវេលាសម្រាប់បណ្តឹងសាទុក្ខដែរ។ ញត្តិទាំងនេះមួយភាគធំ គឺជាលទ្ធផលនៃការដាក់បង្ហាញភ័ស្តុតាងដែលកំពុងតែដំណើរការទៅក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលញត្តិចុងក្រោយគេបង្អស់ត្រូវ បានដាក់នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០១៥ ហើយជាលទ្ធផលនៃ ការដាក់បង្ហាញភ័ស្តុតាងដែលកំពុងបន្តធ្វើឡើងនៅក្នុងសំណុំរឿង ០០២/០២ នៅចំពោះមុខអង្គជំនុំ ជម្រះសាលាដំបូង។ ដោយសារមានសំណើសុំភ័ស្តុតាងបន្ថែមនេះ ហើយ ទើបអង្គជំនុំជម្រះតុលាការ កំពូលបានសម្រេចមួយចំនួន ក្នុងនោះរួមមានការចាប់ផ្តើមធ្វើការស៊ើបអង្កេតបន្ថែមមួយចំនួនតូច ព្រមទាំងកោះហៅសាក្សីសាក្សីបីនាក់លើបណ្តឹងសាទុក្ខ។ សវនាការស្តាប់សក្ខីកម្មរបស់សាក្សីចំនួនបី នាក់នេះបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២ ដល់ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០១៥។ ការស៊ើបអង្កេតបន្ថែមត្រូវ បានបញ្ចប់នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ នៅពេលដែលអង្គជំនុំ ជម្រះតុលាការកំពូលចេញនូវសេចក្តី សម្រេចទៅលើសំណើដែលនៅសេសសល់ទាំងឡាយស្នើសុំភស្តុតាងបន្ថែម។

៤៤ ការលំបាកមួយដែលនឹកស្មានមិនដល់នោះគឺបានកើតឡើងនៅពេលសវនាការបណ្តឹងសាទុក្ខ ដែលពេល នោះ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់កាលបរិច្ឆេទសវនាការពីថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ប៉ុន្តែឃើញខ្លួនខ្លួនគ្មានជម្រើសក្រៅពីផ្អាកសវនាការនៅថ្ងៃដំបូង។ មូលហេតុគឺខ្វះតំណាង ផ្លូវច្បាប់សម្រាប់ ជនជាប់ចោទ នួន ជា ដោយហេតុថា មេធាវីដែលចាត់តាំង សម្រាប់ការពារក្តីនួន ជាមិនបានចូលរួមសវនាការពេញលេញ ដោយអះអាងថាធ្វើតាមការណែនាំ របស់ ជនជាប់ចោទក្នុង ការធ្វើពហិការ។ អង្គជំនុំជម្រះតុលាការកំពូល ក៏សម្រេចចាត់តាំងមេធាវីប្រចាំការ សម្រាប់ នួនជា ដើម្បីធានាថាដំណើរការនីតិវិធី អាចបន្តដោយគ្មានការបង្អាក់ ដោយមិនគិតដល់ការប្រព្រឹត្តបែបនេះ ទៀត របស់ មេធាវី នួន ជា បច្ចុប្បន្ន។ ក្រោយពីមានការចាត់តាំងមេធាវីប្រចាំការ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និង ដោយពិចារណាដល់ការចាំបាច់ក្នុងការផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់គាត់រៀបចំ ការការពារក្តី អង្គជំនុំជម្រះតុលាការកំពូល បានបើកសវនាការបណ្តឹងសាទុក្ខនៅថ្ងៃទី១៦-១៨ ខែកុម្ភៈ ឆ្នាំ ២០១៦ ដែលខណៈនោះ អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមពិភាក្សាសម្រេច និងព្រាង សាលដីកា។

៤៥ ចូរកត់សម្គាល់ជាពិសេសទៅលើកាលៈទេសៈពិសេសរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលត្រូវដោះស្រាយទៅលើសេចក្តីសម្រេចមួយចំនួន ភាគច្រើនពាក់ព័ន្ធនីតិវិធី ដែលសេចក្តីសម្រេចទាំងនោះបានធ្វើឡើងនៅក្នុងកិច្ចនីតិវិធីសវនាការ ដែលអាចប្តឹងសាទុក្ខបានតែក្រោយចេញសាលក្រមប៉ុណ្ណោះ។ ប្រការនេះមិនដូចគ្នាទៅនឹងស្ថានភាពនៅតុលាការព្រហ្មទណ្ឌអន្តរជាតិឬ សាលាក្តីមិនអចិន្ត្រៃយ៍នោះទេ ដែលនៅទីនោះ គេមានលទ្ធភាពដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំទៅលើសេចក្តីសម្រេច ពោលគឺ នៅខណៈពេលមានសវនាការ ដើម្បីដោះស្រាយវិវាទនានាដែលកើតឡើង។ ប៉ុន្តែ អនុលោមតាមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង អវតក យុត្តាធិការបណ្តឹងសាទុក្ខ នៅអំឡុងពេលនីតិវិធីសវនាការ គឺមានតិចតួចណាស់។ ដូច្នេះ ក្រោយពីមានការវិភាគទៅលើសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ បង្ហាញច្បាស់ថា អង្គជំនុំជម្រះតុលាការកំពូលឥឡូវនេះគឺត្រូវលះបង់ពេលវេលារបស់ខ្លួនប្រមាណ៥០% ដើម្បីពិនិត្យពិច័យទៅលើបញ្ហាទាំងឡាយ ដែលអាចត្រូវបានដោះស្រាយបានមុន ដូចនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬសាលាក្តីមិនអចិន្ត្រៃយ៍។

៤៦ ដោយពិចារណាទៅលើកត្តាទាំងនេះ និង បទពិសោធន៍ដែលពាក់ព័ន្ធរបស់តុលាការអន្តរជាតូបនីយកម្ម និងតុលាការអន្តរជាតិ និងសាលាក្តីនានាដែលមានសំណុំរឿង ដែលមាន ទំហំ និង ភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា ការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតមកដល់ពេលនេះគឺថា ដំណើរការបណ្តឹងសាទុក្ខប្រហែលជាអាច ត្រូវបញ្ចប់យ៉ាងឆាប់បំផុតគឺនៅចុងត្រីមាសទី២ក្នុងឆ្នាំ២០១៦។ ក្រោយពីទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារទីប្រឹក្សាសំខាន់ម្នាក់ដែលចូលរួមរៀបចំសាលដីកា និង អវត្តមានដោយមូលហេតុសុខភាព បច្ចុប្បន្នអង្គជំនុំជម្រះតុលាការកំពូល រំពឹងថាការចេញសាលដីកានឹងប្រព្រឹត្តទៅនៅត្រីមាសទី៣ ឆ្នាំ២០១៦។ ប៉ុន្មានខែបន្ទាប់ទៀត នឹងចូលរួមពិភាក្សាសម្រេចបន្ថែមទៀត និងធ្វើសេចក្តីព្រាងសាលដីកា។ កាលបរិច្ឆេទប្រកាសសាលដីកា នឹងជូនដំណឹងប៉ុន្មានសប្តាហ៍មុន។

៤៧ ពាក់ព័ន្ធនឹងវិធានការបន្ទាប់ នៅក្នុងដំណើរការបណ្តឹងសាទុក្ខ ក្នុងរយៈពេលប៉ុន្មានខែខាងមុខ នឹងមានការពិនិត្យបន្ថែមទៀតទៅលើ ឯកសារទាំងអស់ ដែលបានដាក់ ការធ្វើសេចក្តីព្រាង ឯកសាររៀបចំសវនាការ និងការធ្វើសវនាការលើបណ្តឹងសាទុក្ខ។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលនឹងបញ្ចប់ការពិភាក្សាសម្រេច និងរៀបចំចេញសាលដីកាក្នុងសំណុំរឿង ០០២/០១។

## ខ. សំណុំរឿង០០២/០២

៤៨ សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូច ជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្តឹងសាទុក្ខ(ទាំងឡាយ)ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២នឹងមានលក្ខណៈស្មុគស្មាញនិងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និង កត្តានានា ដូចជាសំណើសុំ ពន្យារពេលក្នុងការដាក់សារណា ឬញត្តិដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ទំហំការងារបែបនេះនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការក្រោយពេលមានការដាក់បណ្តឹងសាទុក្ខ ។

៤៩ ជាងនេះទៅទៀត បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង០០២/០១ គិតជាមធ្យម រំពឹងថាមានបណ្តឹងសាទុក្ខភ្លាមៗចំនួនមួយផងដែរក្នុងមួយខែក្នុងរយៈពេលមាននីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២។ ប្រការនេះអាចធ្វើឲ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែធំឡើង ហើយ ប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកា លើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

## VI. សេចក្តីសន្និដ្ឋាន

៥០ សម្រាប់ឆ្នាំ២០១៦ គេរំពឹងថា ព្រឹត្តិការណ៍ចំនួន២នឹងត្រូវសម្រេចបានក្នុងសំណុំរឿង០០២/០១ និង ០០២/០២៖ (i) ការចេញសាលដីកាក្នុងសំណុំរឿង០០២/០១ និង (ii) ការបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២។ ចំពោះសំណុំរឿង០០៣ និង ០០៤ មានការរំពឹងថា នឹងសម្រេចបានព្រឹត្តិការណ៍ចំនួន៤៖ (i)សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ii)ការចេញដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ ជាមួយនឹង សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំ រឿងទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចនីតិវិធីតែម្តង។ (iii) សេចក្តីជូន

ដំណើងអំពីការបញ្ចប់កិច្ចស៊ើបសួរសម្រាប់ជនត្រូវចោទដែលនៅសេសសល់ក្នុងសំណុំរឿង០០៤ និង (iv)ការចេញដីកាដំណោះស្រាយក្នុង សំណុំរឿង០០៤ប្រឆាំងនឹង អោ អាន និង សំណុំរឿង០០៤/០១ ប្រឆាំងនឹង អ៊ុម ចែម ជាមួយនឹងសេចក្តីសម្រេច របស់សហចៅ ក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូន សំណុំរឿង ទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៥១ សម្រាប់ឆ្នាំ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ចំនួន២ក្នុងសំណុំរឿង ០០២/០២ ពោលគឺ៖ (i) ការចេញសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និង (ii) ការចេញ សាលក្រមលើ សំណុំរឿង ០០២/០២។ ក្នុងសំណុំរឿង០០៣ និង ០០៤ រំពឹងថានឹង សម្រេច បានគ្រោង ការសំខាន់ចំនួន ៣បន្ថែមទៀតគឺ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ដំណោះស្រាយ ក្នុងសំណុំរឿង ០០៣ និង (ii) ការចេញដីការដំណោះស្រាយ ក្នុងសំណុំរឿង០០៤ ប្រឆាំង យឹម ទិត្យ និង (iii)ការ សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុង សំណុំរឿង០០៤ ជាមួយនឹងសេចក្តី សម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះ ទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ត្រូវបានបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬ ដោយផ្នែកការព្យាករណ៍ ទុកនូវតារាងកំណត់ពេលវេលា ក្នុងសំណុំរឿងទាំងនេះគឺអាច យកមកវាយតម្លៃបាន។

៥២ ក្នុងអំឡុងឆ្នាំ ២០១៨ មានការរំពឹងទុកថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ចំនួន១ ក្នុងសំណុំរឿង ០០២/០១។ កាលបរិច្ឆេទចុងក្រោយសម្រាប់បណ្តឹងសាទុក្ខ។ ក្នុងករណីមានបណ្តឹងសាទុក្ខ ក្នុង សំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការ ពិភាក្សាសម្រេចក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៥៣ សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ចំនួន១ គឺ ៖ (i) ការចេញ សាលដីកាលើសំណុំរឿង០០២/០២។

៥៤ ការស្មានទុកនូវព្រឹត្តិការណ៍សំខាន់ៗ ដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ ជូនជាមួយនឹងផែនការនេះស្រាប់។

# តារាងកំណត់ពេលវេលាតាមការគ្រោងទុក ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

